# សេចក្តីថ្លែងការណ៍រួម
# «ការអនុញ្ញាតឲ្យជនបរទេសប្រកបមុខរបរស្វ័យនិយោជន៍ គឺការដណ្តើមមុខរបររបស់កម្មករ និងប្រជាពលរដ្ឋខ្មែរ»

ថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
*ត្រូវនឹងថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៩*

យើងខ្ញុំទាំងអស់គ្នាជាសហជីព សមាគម និងអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការជាមួយកម្មករក្នុងប្រព័ន្ធ ប្រជាពលរដ្ឋកម្ពុជាពិសេសកម្មករវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬកម្មករស្វ័យនិយោជន៍ ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស មុខរបរ និងជីវភាពរស់នៅរបស់បងប្អូនកម្មករ កម្មការិនី និងប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជាមានការខកចិត្តយ៉ាងខ្លាំង ដែលបានឃើញសេចក្តីជូនដំណឹង **លេខ០៣៥** របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី៥ ខែ តុលា ឆ្នាំ ២០១៩ **ស្តីអំពី«ការអនុញ្ញាតឡើងវិញនៃសកម្មភាពស្វ័យនិយោជន៍ដោយជនបរទេស»** ។ កន្លងមកសហជីព សមាគម និងអង្គការសង្គមស៊ីវិលយើងមានការសារទរ ចំពោះប្រកាសលេខ **៣៦០ ស្តីពីការកំណត់ប្រភេទមុខរបរ និងការងារដែរត្រូវហាមឃាត់ចំពោះជនបរទេស** ដែលចេញផ្សាយ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១៩ ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការធានាបាននូវការលើកកម្ពស់សិទ្ធិសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតទៅតាមជំនាញរបស់ខ្លួនក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬ កម្មករស្វ័យនិយោជន៍។

យើងខ្ញុំមានការខកចិត្តយ៉ាងខ្លាំង ចំពោះសេចក្តីប្រកាស**ស្តីអំពី«ការអនុញ្ញាតឡើងវិញនៃសកម្មភាពស្វ័យនិយោជន៍ដោយជនបរទេស»** ដែលអាចប្រកបមុខរបរស្វ័យនិយោជន៍នៅក្នុងប្រទេសកម្ពុជាដូចកម្មករ និងប្រជាពលរដ្ឋខ្មែរទូទៅ ដែលនេះមិនមែនជាការទាក់ទាញការវិនិយោគបរទេសទេ តែបានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កម្មករ និងប្រជាពលរដ្ឋកម្ពុជាដែលកំពុងប្រកបមុខរបរវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬកម្មករស្វ័យនិយោជន៍ដោយប្រើប្រាស់លទ្ធភាពខ្លួនឯងប្រកបមុខរបរចិញ្ចឹមជីវិតជាលក្ខណគ្រួសារ និងនៅតាមសហគមន៍របស់ពួកគេ ដូចជាអ្នករត់ម៉ូតូឌុប តាក់ស៊ី អ្នកលក់ដូរតាមដងផ្លូវ អ្នកកែសម្ផស្ស ម៉ាស្សា អ្នកលក់គ្រឿងចំណីអាហារបរិភោគ អ្នកប៉ះកង់ និងអ្នកបើកអាជីវកម្មតូចតាចគ្រប់ប្រភេទដែលជាទំនៀមទំលាប់នៅទូទាំងប្រទេសកម្ពុជា។ យោតាមសេចក្តីជូនដំណឹងនេះដែលមានការអនុញ្ញត្តិឲ្យជនបរទេសប្រកបមុខរបរស្វ័យនិយោជន៍ គឺជាការបើកឱកាសឲ្យជនបរទេសមកធ្វើការ**«ដណ្តើមមុខរបរបស់កម្មករ និងប្រជាពលរដ្ឋខ្មែរ»** ព្រោះប្រជាពលរដ្ឋ និងកម្មករវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬ កម្មករស្វ័យនិយោជន៍ប្រឈមការបាត់បង់នូវប្រាក់ចំនូល បាត់បង់អតិថិជន បាត់បង់មុខរបរ និងធ្វើឲ្យជីវភាពភាពគ្រួសាររស់នៅទាំងមូលលំបាកដុនដាប ហើយត្រូវបង្ខំចិត្តចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសដើម្បីប្រកបមុខរបរចិញ្ចឹមជីវិត។

**ការអនុញ្ញាតឡើងវិញនៅនៃសកម្មភាពស្វ័យនិយោជន៍ដោយជនបរទេស** នេះមិនស្របតាមគោលនយោបាយយុទ្ធសាស្រ្តចតុកោណក្នុងដំណាក់កាលទី៤ របស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា ពិសេសប្រជាពលរដ្ឋ និងកម្មករវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ឬ កម្មករស្វ័យនិយោជន៍ហើយហាក់បីដូចជាផ្ទុយគោលនយោបាយជាតិកិច្ចគាំពារសង្គមរបស់រាជរដ្ឋាភិបាល ឆ្នាំ២០១៦-២០២៥ ដែលជានាក្នុងការលើកម្ពស់ជីវភាព មុខរបរ និងសុខភាពរបស់ប្រជាពលរដ្ឋ និងកម្មករវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬ កម្មករស្វ័យនិយោជន៍។

ដោយឡែកសម្រាប់ការទាក់ទាញការវិនិយោគគឺសំដៅដល់ជនបរទេសដែលវិនិយោគទៅលើក្រុមហ៊ុនធំៗដូចជាវិស័យកាត់ដេរសម្លៀកបំពាក់និងដេរស្បែកជើង សណ្ឋាគារ អាកាសចរណ៍ ឧសហកម្មសំណង់ និងអ្នកជំនាញជាន់ខ្ពស់ទាំងអស់នេះគឺយើងស្វាគមន៍ ប៉ុន្តែយើងខ្ញុំមិនស្វាគមន៍ចំពោះការផ្តល់ឱកាសអោយជនបរទេសជនស្វ័យនិយោជន៍ ឬជាបុគ្គលដែលប្រកបមុខរបរដោយខ្លួនឯងក្នុងប្រទេសកម្ពុជានោះទេ។

ដូច្នេះយើងខ្ញុំទាំងអស់គ្នាជាសហជីព សមាគម និងអង្គការសង្គមស៊ីវិលលើកទឹកចិត្តអោយរដ្ឋាភិបាលក៏ដូចជាក្រសួងពាក់ព័ន្ធសូមពិចារណា និងលុបចោលលើសេចក្តីជូនដំណឹងមួយនេះហើយងាកមកធ្វើការអនុវត្តន៍ទៅតាមប្រកាសលេខ **៣៦០ ស្តីពីការកំណត់ប្រភេទមុខរបរ និងការងារដែរត្រូវហាមឃាត់ចំពោះជនបរទេស** ដែលចេញផ្សាយកាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១៩ ដើម្បីជានាការលើកកម្ពស់ជីវភាព និងប្រកបមុខរបរដោយនិរន្តភាពរបស់ប្រជាពលរដ្ឋ និងកម្មករវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬកម្មករស្វ័យនិយោជន៍។

យើងខ្ញុំក៏គាំទ្រ រាល់គោលនយោបាយរដ្ឋាភិបាល ក្នុងការវិនិយោគទុនធំៗក្នុងការវិនិយោគក្នុងប្រទេសកម្ពុជាក្រៅពីមុខរបរស្វ័យនិយោជន៍មួយនេះដោយនាំមកនូវអត្ថប្រយោជន៍សម្រាប់ កម្មករ កម្មការិនី ប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូល។

**ឈ្មោះសហជីព សមាគម សហគមន៍ និងអង្គការសង្គមស៊ីវិលគាំទ្រសេចក្តីថ្លែងការណ៍នេះ**

១- សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ(IDEA)
២- សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
៣- សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា(CFSWF)
៤- សមាគមបណ្តាញយុវជនកម្ពុជា(CYN)
៥- សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា(CICA)
៦- សហព័ន្ធសាមគ្គីចលនាកម្មករចំណាក់ស្រុកកម្ពុជា(CMA)
៧- សមាគមកម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ(CIWA)
៨- សហព័ន្ធសហជីពឯករាជ្យ(INTUFE)
៩- សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរក្រុមហ៊ុនណាហ្គាវើលដ៍
១០- សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA)
១១- សមាគមសម្ព័ន្ធនិសិត្សបញ្ញាវ័ន្តខ្មែរ (SLIKA)
១២- អង្គការក្រុមការងារពិសេសការពារសិទ្ធិមនុស្សកម្ពុជា(CHRTF)
១៣- សហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនកម្ពុជា(CTWF)
១៤- វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ(API)
១៥- អង្គការគាំទ្របច្ចេកវិទ្យានៅជនបទក្នុងប្រទេសកម្ពុជា(RCTSO)
១៦- អង្គការសម្ព័ន្ធការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)

១៧- កម្មវិធី អភិវឌ្ឍន៍ធនធានយុវជន (YRDP)
១៨- សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា(CTWUF)
១៩- អង្គការសម្ព័ន្ធភាពការងារកម្ពុជាដើម្បីសិទ្ធិមនុស្ស(CENTRAL)
២០- សហព័ន្ធសហជីពជាតិកម្ពុជា (CATU)
២១- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR)
២២- សហភាពសជីពជាតិកម្ពុជា (CCU)
២៣- សហភាពផ្ទះសាមគ្គី (Solidarity House Confederation)
២៤- សហព័ន្ធសហជីពវិស័យឧស្សាហកម្មកម្ពុជា(CIWF)
២៥- សហភាពការងារកម្ពុជា (CLC)
២៦- សហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជា(BWTUC)
២៧- សហព័ន្ធសហជីពកម្មករនិយោជិកវិស័យទេសចរណ៍ និងសេវាកម្មកម្ពុជា(CTSWF)
២៨- អង្គការពន្លកខ្មែរ (PKH)
២៩- គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា(COMFREL)
៣០- អង្គការសមាគមជាងត្នោត (STT)
៣១- សហគមន៍ស្រែប្រាំ ខេត្តត្បូងឃ្មុំ
៣២- សហគមន៍កំប្រើស ខេត្តត្បូងឃ្មុំ
៣៣- សហគមន៍បុស្សស្នោ ខេត្តត្បូងឃ្មុំ
៣៤- សហគមន៍ដីធ្លីជណ្តួងត្របែក ខេត្តស្វាយរៀង
៣៥- សហគមន៍សាមគ្គីមោសហែក ខេត្តស្វាយរៀង
៣៦- សហគមន៍មានជ័យ ខេត្តស្វាយរៀង
៣៧- សហគមន៍សាមគ្គីចេកមាស ខេត្តស្វាយរៀង
៣៨- សហគមន៍អូរខ្សាច់ ខេត្តព្រះសីហនុ
៣៩- សហគមន៍ព្រែកត្រែង ខេត្តព្រះសីហនុ
៤០- សហគមន៍អូរជំរឺ ខេត្តព្រះសីហនុ
៤១- សហគមន៍អូរកម្ពុជា ខេត្តព្រះសីហនុ
៤២- សហគមន៍ក្បាលហុងទឹក ខេត្តព្រះសីហនុ
៤៣- សហគមន៍ថ្មធំ ខេត្តព្រះសីហនុ
៤៤- សហគមន៍អណ្តូងថ្ម ខេត្តព្រះសីហនុ
៤៥- សហគមន៍បាតខ្វះ ខេត្តព្រះសីហនុ
៤៦- សហគមន៍សេអ៊ីប្រាំ ខេត្តព្រះសីហនុ
៤៧- សហគមន៍អូរត្រជាក់ចិត្ត ខេត្តព្រះសីហនុ
៤៨- សហគមន៍ស្ពានឆេះ ខេត្តព្រះសីហនុ
៤៩- សហគមន៍ស្មើសាមគ្គី ខេត្តកំពង់ស្ពឺ
៥០- សហគមន៍ត្រពាំងជោ ខេត្តកំពង់ស្ពឺ
៥១- សហគមន៍អមលាំង ខេត្តកំពង់ស្ពឺ